# កម្សាន្តសប្បាយដោយការទទួលខុសត្រូវនៅសួនឧទ្យានរដ្ឋ

*គោលការណ៍ណែនាំសម្រាប់ការកម្សាន្តដោយការទទួលខុសត្រូវនៅខាងក្រៅផ្ទះ*

## មុនពេលអ្នកទៅ

- សូមពិនិត្យមើលអ្វីដែលបើក។ ក្នុងខណៈដែលគោលដៅតំបន់ដីធ្លីដែលគ្រប់គ្រងដោយរដ្ឋជាច្រើនបើកសម្រាប់ការប្រើប្រាស់ពេលថ្ងៃ តំបន់ដីធ្លីក្នុងមូលដ្ឋាន របស់កុលសម្ព័ន្ធ និងសហព័ន្ធដទៃទៀតអាចនឹងនៅតែបិទដដែល។ សូមចូលមើលតាមអនឡាញលើគេហទំព័រ www.parks.state.wa.us/parksopening
- ជ្រើសរើសយកការធ្វើដំណើរវិលល្ងាចដែលជិតផ្ទះ។ ការស្នាក់នៅមួយយប់មិនត្រូវបានអនុញ្ញាតទេ។
- ស្នាក់នៅជាមួយសមាជិកក្រុមគ្រួសារផ្ទាល់តែប៉ុណ្ណោះ។ ការកម្សាន្តជាមួយអ្នកទាំងឡាយណាដែលនៅខាងក្រៅក្រុមគ្រួសាររបស់អ្នកបង្កើតនូវមធ្យោបាយថ្មីសម្រាប់ការចម្លងវីរុស។
- មកដោយមានការត្រៀមរៀបចំ។ ភ្ញៀវទស្សនាអាចនឹងរកឃើញសេវាកម្មបន្ទប់ទឹកដែលថយចំនួន ឬមានកំណត់ដោយសារបុគ្គលិកចាប់ផ្តើមដំណើរការដើម្បីបើកកន្លែងឡើងវិញនៅតំបន់សត្វព្រៃ និងទីចូលទៅកាន់ទឹក។ អ្នកត្រូវបានណែនាំឲ្យនាំយកមកនូវសាប៊ូ ទឹក ទឹកលាងដៃ និងក្រដាសអនាម័យផ្ទាល់របស់អ្នក ក៏ដូចជាម៉ាស់ ឬក្ដូនកន្សែងធំដើម្បីគ្របច្រមុះ និងមាត់របស់អ្នក។
- រីករាយកម្សាន្តនៅខាងក្រៅផ្ទះពេលមានសុខភាពល្អ។ ប្រសិនបើអ្នកមានរោគសញ្ញាគ្រុនក្តៅ ក្អក ឬដង្ហក់ សូមទុកការផ្សងព្រេងនៅខាងក្រៅរបស់អ្នកសម្រាប់ថ្ងៃក្រោយមួយទៀត។

## ពេលអ្នកទៅដល់ទីនោះ

- ចៀសវាងហ្វូងមនុស្សកកកុញ។ សូមត្រៀមឲ្យរួចរាល់ដើម្បីទៅកន្លែងផ្សេងទៀត ឬត្រឡប់មកវិញនៅពេលមួយផ្សេងទៀតប្រសិនបើទីគោលដៅរបស់អ្នកមើលទៅអ៊ូអរកកកុញ។

- អនុវត្តការរក្សាគម្លាត។ រក្សាគម្លាត 6 ហ្វីតរវាងអ្នក និងអ្នកទាំងឡាយដែលនៅក្រៅក្រុមគ្រួសារផ្ទាល់របស់អ្នក។ បញ្ឈរទូកម្តងមួយៗដើម្បីផ្តល់ដល់អ្នកដទៃនូវចន្លោះទីលំហគ្រប់គ្រាន់ដើម្បីបើកបញ្ឈរដោយសុវត្ថិភាព។ ទុកចោលយ៉ាងហោចណាស់ទីលំហចំណតមួយកន្លែងរវាងយានជំនិះរបស់អ្នក និងយានជំនិះនៅបន្ទាប់នឹងអ្នក។ សណ្តោងទូករបស់អ្នកនៅក្នុងរបៀបដដែលដូចគ្នា។
- លាងដៃរបស់អ្នកឲ្យបានញឹកញាប់។ បន្តអនាម័យផ្ទាល់ខ្លួន ហើយនាំយកនូវទឹក សាប៊ូ និងទឹកលាងដៃផ្ទាល់របស់អ្នកមកជាមួយអ្នក។
- វេចខ្ចប់យកចេញនូវអ្វីដែលអ្នកបានវេចខ្ចប់យកចូល។ យកសំរាមណាមួយទៅជាមួយអ្នករួមមានដូចជាស្រោមដៃ និងម៉ាស់ប្រើរួចបោះចោល។
- សូមមានចិត្តល្អ និងគោរពចំពោះមេព្រៃ ជំនួយការចំណត និងបុគ្គលិកនៅផ្ទាល់ជាប់នឹងមូលដ្ឋានរបស់យើង។

សម្រាប់ព័ត៌មានអំពីការឆ្លើយតបរបស់រដ្ឋ Washington state ទៅនឹងជំងឺ COVID-19 សូមចូលមើលគេហទំព័រ www.coronavirus.wa.gov។

សម្រាប់ព័ត៌មានបន្ថែមស្តីអំពីការឆ្លើយតបរបស់ Washington State Parks ទៅនឹងជំងឺ COVID-19 សូមចូលមើលគេហទំព័រ www.parks.state.wa.us/COVID19។